ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះវិហារ

សាលក្រមលេខ:៨៦.ខ.

ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦

សំណុំរឿងព្រហ្មទណ្ឌលេខ:៧៨

ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៦

## តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តព្រះវិហារ បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ដោយមានសមាសភាពតុលាការនាពេលសវនាការពិភាក្សាសម្រេច និងប្រកាស-សាលក្រមដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងខេត្តព្រះវិហារ។

លោក [redacted] ចៅក្រមប្រឹក្សានៃសាលាដំបូងខេត្តព្រះវិហារ។

លោកស្រី [redacted] ចៅក្រមប៊ក្សានៃសាលាដំបូងខេត្តព្រះវិហារ។

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះវិហារ។

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តព្រះវិហារ។

### មេធាវី

លោក [redacted] ជាមេធាវីការពារជនជាប់ចោទ។

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ:៧៨ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ:

ឈ្មោះ [redacted] ប៉ាត ភេទប្រុស អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិឈូក ឃុំភ្នំត្បែងពីរ ស្រុកគូលែន ខេត្តព្រះវិហារ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តព្រះវិហារ ស្ថានភាពគ្រួសារ មានប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៥នាក់ មានឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) មុខរបរកសិករ កម្រិតវប្បធម៌គ្មាន ប្រវត្តិផ្តន្ទាទោសពីមុនគ្មាន ជានីតិជន។

ជាប់ចោទពីបទ: រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិក្តី ឃុំអោង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ បទល្មើសដែលមានបញ្ញាត្តិអោយផ្តន្ទាទោសតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី ទាមទារសំណងចំនួន៣,០០០,០០០ (បីលាន)រៀល។

អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ មានករណីរំលោភសេពសន្ថវៈស្ថិតនៅចំណុចអូរប៉ុច ភូមិក្តី ឃុំអោង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដែលបង្កឡើងដោយឈ្មោះ [redacted] ប៉ាត់ បានដើរទៅដេញគោតែនាពេលខ្លួនបានដើបានពាក់កណ្តាលផ្លូវស្រាប់តែឃើញជនរងគ្រោះឈ្មោះ [redacted] កំពុងតែដងទឹកមកផ្ទះ បន្ទាប់មកខ្លួនក៏ចាប់ផ្តួលទៅនឹងដី ហើយធ្វើសកម្មភាពរំលោភសេពសន្ថវៈតែម្តង។



Scanned by CamScanner

បានឃើញៈដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខៈ១៨១៦ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ

បានឃើញៈសំណុំរឿងព្រហ្មទណ្ឌលេខៈ៧៨ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦ នៃសាលាដំបូងខេត្តព្រះវិហារ

បានឃើញៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ៧៦ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ

បានឃើញៈសំណុំរឿងឲ្យស៊ើបសួរលេខៈ៧១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ

បានឃើញៈដីកាសន្និដ្ឋានស្ថាពរលេខៈ១០៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ របស់អយ្យការអមសាលា_ដំបូងខេត្តព្រះវិហារ

បានឃើញៈដីកាសម្រេចដាក់សំណុំរឿងទៅជម្រះលេខៈ១៧០៦ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តព្រះវិហារ

**<u>នាពេលសវនាការ</u>**

-លោកមេធាវី [redacted] សុក្រា មានវត្តមាន

-ជនជាប់ឈ្មោះ [redacted]ប៉ាត់ មានវត្តមាន

-ដើមបណ្តឹងឈ្មោះ [redacted]ធី អវត្តមាន

-សាក្សីឈ្មោះ [redacted] មឿន អវត្តមាន

-សាក្សីឈ្មោះ [redacted]តនា អវត្តមាន

-ជនជាប់ចោទឈ្មោះ [redacted] ប៉ាត់ ខ្លួនបានសារភាពថា ខ្លួនពិតជាបានធ្វើសកម្មភាពរំលោភសេពសន្ថវៈលើ
ជនរងគ្រោះឈ្មោះ [redacted] ធី ពិតប្រាកដមែន ដោយនៅពេលនោះខ្លួនបានផឹកស្រានៅផ្ទះ ហើយទៅដឹកគោនៅព្រៃ
ហើយក៏ចាប់ជនរងគ្រោះរំលោភតែមិនទាន់ចេញទឹកកាមទេ ព្រោះប្រពន្ធទៅទាន់ ហើយខ្ញុំក៏ឈប់ទៅ។ នៅពេល
ចាប់រំលោភនោះ ជនរងគ្រោះមិនបានស្រែកទេ ព្រោះជនរងគ្រោះក៏ស្រវឹងដែរ រំលោភបានប្រហែលបាន០៥នាទី
ប្រពន្ធទៅទះខ្នងខ្លួន ខ្លួនបែរទៅក្រោយឃើញប្រពន្ធ ខ្លួនក៏ដើរចេញ ឯប្រពន្ធខ្លួនក៏ដើរចេញ ចំណែកប្តីជនរងគ្រោះ
មិននៅទីនោះទេគឺទៅព្រៃបាត់ហើយ។ សមត្ថកិច្ចចាប់ខ្លួនកន្លងបានមួយថ្ងៃ ខ្លួនដឹងថាខ្លួនខុសហើយ។ ខ្លួនស្លៀកក្រ
មា៉ និងខោរលីអូ មិនបានពាក់អាវទេ ពេលនោះខ្លួនស្រវឹងពេកមិនដឹងយ៉ាងម៉េចខ្លះទេ។ ខ្លួនមានការសោកស្តា
យណាស់ ខ្លួនជាអ្នករកចំណូលក្នុងគ្រួសារ ពេលខ្លួនត្រូវបានចាប់ខ្លួនមិនមានអ្នករកលុយចិញ្ចឹមគ្រួសារខ្លួនទេ ខ្លួន
មានជំងឺប្រចាំកាយទៀតផង។

-ក្រឡាបញ្ជីបានអានអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ធី ថា នៅថ្ងៃកើតហេតុវេលាម៉ោង០៨
ល្ងាច ខ្លួនពីរនាក់កូនស្រីអាយុ០៧ឆ្នាំ បានទៅដងទឹកនៅអូរជូនប៉ិច ពេលដងទឹកបានហើយក៏ដើរមកផ្ទះក៏ជួបឈ្មោះ
ប៉ាត ហើយគាត់ក៏ដើរមកចាប់អោបខ្លួនតែម្តង ហើយខ្លួនស្រែកថាធ្វើអីអញ្ចឹង តែគាត់មិនឆ្លើយតបនៅតែចាប់ស្រាត
សំពត់ខ្លួន ហើយផ្តួលខ្លួនទៅលើដី និងស្រាតខោរគាត់រួចយក[redacted]គាត់ដាក់ចូលក្នុងប្រដាប់ភេទខ្លួនរយះពេល
ប្រហែល០៥នាទី ក៏ប្រពន្ធគាត់មកទាន់ស្រែកថា អាវង្វេងកុំនិតចោកទាប នឹងយករំពាត់មកវាយទើបឈ្មោះ [redacted]ប៉ាត
រប្[redacted]ចញពីប្រដាប់ភេទខ្លួន ចំណែកកូនខ្លួនក៏យំភ័យពេកស្រែកយំជិតខ្លួន។ ពេលរំលោភខ្លួនរួចឈ្មោះ [redacted] ប៉ាត ក៏
រត់ទៅផ្ទះមុនប្រពន្ធគាត់ទៅ ឯប្រពន្ធគាត់ក៏ទៅងូតទឹក ហើយខ្លួនក៏ទៅដាក់ពាក្យបណ្តឹងតែម្តង។ ជនជាប់ចោទ
ឈ្មោះ [redacted] ប៉ាត ធ្លាប់បានរំលោភនាងខ្លួនពីរដងទាំងលើកនេះ លើកទី១គឺប្រែលជាង១០ឆ្នាំមុនពេលនាងខ្លួនស្រ
វឹង ខ្លួននិយាយថា តាប៉ាត ឯងទិញស្រាអោយកន្លះលីតមកអោយរំលោភ ហើយគាត់ក៏ទិញអោយមែន ខ្លួនក៏អោយ



Scanned by CamScanner

រំលោភដែរពេលផឹកស្រាអស់ជាមួយគាត់នៅផ្ទះខ្លួនតែពីរនាក់គាត់ ដោយសារពេលនោះប្តីខ្លួនមិននៅផ្ទះ។ ខ្លួនទាមទាសំណងចំនួន៣,០០០,០០០(បីលាន)រៀល និងសុំអោយឈ្មោះ [redacted]ប៉ាត ទៅផ្ទះវិញ។

-ក្រឡាបញ្ជីបានអានអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] មឿន ថា នៅថ្ងៃកើតហេតុប្តីរបស់ខ្លួនឈ្មោះ [redacted] ម ប៉ាត បានបបួលខ្លួនទៅងូតទឹក ហើយក៏ទៅជាមួយគ្នាពេលទៅដល់កន្លែងងូតទឹកប្តីខ្លួនថា អោយបោយមកអាញ់ ទៅងូតទឹកនៅខាងក្រោម ពេលងូតទឹករួចខ្លួនក៏ដើរទៅរកប្តី ក៏ឃើញប្តីកំពុងរំលោភឈ្មោះ [redacted] ធី ហើយខ្លួនក៏ជេរថា អាមារយាទថ្កែ មីមារយាទថ្កែ និងបានទះស្មាប្តីចំនួន០៤ដៃ ហើយអ្នកទាំងពីរក៏នៅតែមិនរបូតចេញពីគ្នាទៀត ខ្លួនតូចចិត្តខ្លាំងពេកក៏រត់ចេញទៅផ្ទះតែម្តង។ ជនរងគ្រោះមិនបានស្រែកអោយនាងខ្លួនជួយនោះទេ ហើយក៏មិនបានរើបំរាស់ចេញដែរ ហាក់បីដូចជាត្រូវរូបគ្នាអញ្ចឹង។

-ក្រឡាបញ្ជីបានអានអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted]តនា ថា នៅមុនពេលកើតហេតុថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង០៤ល្ងាច ម្តាយខ្លួនឈ្មោះ [redacted] ធី បាននាំខ្លួននិងប្អូនទៅដងទឹកអណ្តូង នៅប្រឡាយជូនប៉ុចលើខ្លួងភ្នំត្បែង ខាងជើងភូមិចំងាយប្រហែល១០០ម៉ែត្រ ដោយម្តាយខ្លួនកាន់ធុងស៊ីប្រូពណ៌សមួយ ពេលទៅដល់បានឆ្លងទៅដងទឹកអណ្តូងនៅកែងខាងក្រោម ពេលងូតទឹករួចហើយក៏ដងទឹកត្រឡប់មកវិញបានប្រហែល១៥ម៉ែត្រក៏ស្រាប់តែឃើញឈ្មោះ [redacted] ប៉ាត ដើរមកស្រាតក្រម៉ាបោះទៅខាងកើតផ្លូវ រួចស្ទុះទៅចាប់ធុងស៊ីប្រូដែលម្តាយខ្លួកំពុងទូលចោល រួចចាប់ផ្តួលម្តាយខ្លួនទៅលើដីដេកផ្ងារ ខ្ទប់មាត់ និងចាប់ស្រាតសំពត់ម្តាយខ្លួនមកក្រោម ពេលនោះម្តាយខ្លួនស្រែកថាជួយផងៗ ឯឈ្មោះ [redacted] ប៉ាត ឡើងដេកលើម្តាយខ្លួនធ្វើចលនាចុះឡើងៗ ខ្លួន និងប្អូនស្រែកយំប្រហែល១០នាទី ឃើញឈ្មោះ [redacted] មួន ជាប្រពន្ធរបស់ឈ្មោះ[redacted]ប៉ាត កាន់ដំបងមួយហើយជេរប្តីថា អាត្រូវគ្រាប់ត្រូវមីន ហើយវាយប្តីគាត់មួយដំបងត្រូវចង្កេះ ហើយឈ្មោះ [redacted] ប៉ាត បានក្រោកចេញពីម្តាយខ្លួនដើរចេញទៅ ហើយម្តាយខ្លួនក្រោកនាំខ្លួន និងប្អូនទៅផ្ទះវិញ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ការជំនុំជម្រះលើសំណុំរឿងនេះ ឃើញថា ឈ្មោះ [redacted] ប៉ាត ត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ ពីបទ: រំលោភសេពសន្ថវៈ តាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិក្តី ឃុំអាង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦។ ឃើញថា នៅថ្ងៃកើតហេតុជនជាប់ចោទឈ្មោះ [redacted] ប៉ាត់ បានដើរទៅដេញគោឃើញជនរងគ្រោះមកពីដងទឹកក៏ធ្វើសកម្មភាពរំលោភសេពសន្ថវៈលើជនរងគ្រោះតែម្តង។ ជនជាប់ចោទឈ្មោះ [redacted] ប៉ាត់ បានសារភាពថា ខ្លួនពិតជាបានរំលោភលើជនរងគ្រោះពិតប្រាកដមែន។ មានភស្តុតាង នឹងបន្ទុកគ្រប់គ្រាន់ដើម្បីកំណត់ពីពិរុទ្ធភាពលើជនជាប់ចោទ តំណាងអយ្យការសុំរក្សាការចោទប្រកាន់ និងសុំអោយតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីរបស់ខ្លួនមានអាយុ៥១ឆ្នាំ មានស្ថានភាពសុខភាពខ្សោយ មានសេដ្ឋកិច្ចគ្រួសារក្រីក្រ បើសិនជាផ្តន្ទាទោសកូនក្តីរបស់ខ្លួនធ្ងន់ធ្ងរនឹងនាំឲ្យកូនក្តីរបស់ខ្លួន មានបញ្ហាខ្លាំងចំពោះគាត់ និងក្រុមគ្រួសារគាត់ ហើយកូនក្តីរបស់ខ្លួនបានសារភាពគ្រប់ដំណាក់កាលនីតិវិធី ដូច្នេះក្នុងនាមជាមេធាវីការពារឲ្យជនជាប់ចោទ សូមស្នើសុំដល់តុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនឲ្យដល់ក្រោមអប្បបរមា និងអនុវត្តន៍ទោសព្យួរដល់កូនក្តីខ្លួនផង។

-ជនជាប់ចោទនិយាយសំដីជាចុងក្រោយខ្លួនសូមសំណូមពរដល់តុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង



Scanned by CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីជាចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សាលាដំបូងខេត្តព្រះវិហារ</u>

## <u>យល់ឃើញថា:</u>

-កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ពិតជាមានករណីរំលោភសេពសន្ថវៈស្ថិតនៅចំណុចអូរប៉ុច ភូមិក្តី ឃុំអោង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដែលបង្កឡើងដោយឈ្មោះ [redacted] ចាំត់ បានដើរទៅដេញគោតែនាពេលខ្លួនបានដើបានពាក់កណ្តាលផ្លូវស្រាប់តែឃើញជនរងគ្រោះឈ្មោះ [redacted] ធី កំពុងតែដងទឹកមកផ្ទះ បន្ទាប់មកខ្លួនក៏ចាប់ផ្តួលទៅនឹងដី ហើយធ្វើសកម្មភាពរំលោភសេពសន្ថវៈលើជនរងគ្រោះឈ្មោះ [redacted] ធី ប្រាកដមែន។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាំត់ មិនមានការប្រែប្រួលតាំងពីនៅដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងនៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះ ថាខ្លួនពិតជាបានដើរទៅដេញគោ បន្ទាប់មកខ្លួនបានដើរទៅងូតទឹក ស្រាប់តែឃើញជនរងគ្រោះកំពុងតែដងទឹកមកផ្ទះ ខ្លួនបានចាប់ផ្តួល ទៅនឹងដី ហើយធ្វើសកម្មភាពរំលោភបានប្រហែល០៥នាទីប្រពន្ធរបស់ខ្លួនបានមកទាន់ បានវាយនិងដេរខ្លួន ហើយខ្លួនក៏ដើរចេញ ខ្លួនមានការសោកស្តាយចំពោះកំហុសរបស់ខ្លួនណាស់ គប្បីតុលាការពិចារណា។

-តំណាងអយ្យការបានធ្វើការសន្និដ្ឋានថា: មានភស្តុតាង នឹងបន្ទុកគ្រប់គ្រាន់ដើម្បីកំណត់ពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ចាំត់ ពីបទៈ រំលោភសេពសន្ថវៈ សុំរក្សាការចោទប្រកាន់ និងសុំអោយតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ តុលាការនឹងពិចារណា។

-មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: ស្នើសុំដល់តុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនឲ្យដល់ក្រោមអប្បបរមា និងអនុវត្តនទោសព្យួរដល់កូនក្តីខ្លួនផង តុលាការនឹងពិចារណា។

-ដើមបណ្តឹងឈ្មោះ [redacted] ធី ស្នើសុំទាមទារសំណង ៣,០០០,០០០ (បីលាន)រៀល និងសុំអោយដោះលែងជនជាប់ចោទ បានត្រឡប់ទៅផ្ទះវិញ តុលាការនឹងពិចារណា។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាំត់ មានភាពស៊ីចង្វាក់គ្នាទៅនឹងចម្លើយរបស់ជនរងគ្រោះ និងចម្លើយរបស់សាក្សី រួមទាំងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង អាចឲ្យតុលាការជឿជាក់បានថា ជនជាប់ឈ្មោះ [redacted] ចាំត់ ពិតជាបានធ្វើសកម្មភាពរំលោភសេសន្ថវៈលើជនរងគ្រោះឈ្មោះ [redacted] ធី ពិតប្រាកដមែន គប្បីតុលាការពិចារណា។

-មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចាំត ភេទប្រុស អាយុ៥១ឆ្នាំ ពីបទៈ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅចំណុចភូមិក្តី ឃុំអោង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការពិចារណា។

-ពុំមានភស្តុងតាងណាមួយបញ្ជាក់ជនជាប់ចោទ មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាក ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន គប្បីតុលាការពិចារណា។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងប៉ះពាល់ដល់កេត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះដែលច្បាប់បានការពារតាមបញ្ញត្តិមាត្រា២៣៩នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គប្បីតុលាការពិចារណា។



Scanned by CamScanner

## ហេតុដូច្នេះសាលាដំបូងខេត្តព្រះវិហារ
## វិនិច្ឆ័យសេចក្តី

១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ប៉ាត ភេទប្រុស អាយុ៥១ឆ្នាំ (ដែលមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន០៥(ប្រាំ)ឆ្នាំ ពីបទៈ រំលោភសេពសន្ថវៈ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិក្តី ឃុំរអាង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦។

២.បង្គាប់ឲ្យឈ្មោះ [redacted] ប៉ាត ភេទប្រុស អាយុ៥១ឆ្នាំ បង់សំណងឲ្យទៅជនរងគ្រោះឈ្មោះ [redacted] ធី ចំនួន ៣,០០០,០០០ (បីលាន)រៀល ទាមទារលើសពីនេះបដិសេធចោល។

៣.សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១៦ សម្រេចសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ប៉ាត កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធី ទុកសិទ្ធិឲ្យភាគីដែលអវត្តមានប្តឹងទាស់ និងទុកសិទ្ធិឲ្យភាគីឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា [redacted] | ហត្ថលេខានិងត្រាៈ [redacted] | ហត្ថលេខានិងត្រា [redacted] | ហត្ថលេខានិងត្រា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ព្រះវិហារ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned by CamScanner